លេខអនុម័ត
លេខ117079

# ការស្រាវជ្រាវអំពីស្ថានភាពជាក់ស្តែង នៃគ្រួសារពហុវប្បធម៌ទូទាំងប្រទេស ឆ្នាំ 2021

## 2.ស្ត្រីរៀបការអ្នកចូលសញ្ជាតិជាដើម

**ច្បាប់ស្តីពីស្ថិតិ មាត្រាទី33(ការរក្សាការសម្ងាត់)**

① គ្រប់ចំណុចដែលទទួលបាននៅក្នុងតំណាក់កាលនៃការបំពេញស្ថិតិដែលសំដៅលើចំណុចដែលស្ថិតក្នុងការសម្ងាត់របស់បុគ្គល នីតិបុគ្គល ឬ សហគមន៍ត្រូវតែរក្សាការសម្ងាត់។

② ឯកសារដែលពាក់ព័ន្ធនឹងការសម្ងាត់របស់បុគ្គល នីតិបុគ្គល ឬ សហគមន៍នៅពេលធ្វើស្ថិតិ មិនអាចប្រើប្រាស់ក្នុងគោលបំណងផ្សេងក្រៅពីការបំពេញស្ថិតិឡើយ។

ក្រសួងកិច្ចការនារីនិងគ្រួសារធ្វើការអនុវត្ត「**ការស្រាវជ្រាវអំពីស្ថានភាពជាក់ស្តែងនៃគ្រួសារពហុវប្បធម៌ទូទាំងប្រទេស ឆ្នាំ2021**」ក្នុងគោលបំណងយកទៅប្រើប្រាស់ជាឯកសារបង្កើតគោលនយោបាយសម្រាប់ផ្តល់ការគាំពារដល់គ្រួសារពហុវប្បធម៌។
ការស្រាវជ្រាវលើកនេះគឺអនុវត្តន៍ដោយយោងតាម**ច្បាប់ស្តីពីការគាំគ្រួសារពហុវប្បធម៌** ដូច្នេះហើយ ប្រសិនបើមន្ត្រីស្រាវជ្រាវចុះទៅលំនៅដ្ឋានរបស់លោកអ្នក សូមមេត្តា**ចូលរួមសហការផង។**

※ ដោយយោងតាម**ច្បាប់ស្តីពីស្ថិតិ មាត្រាទី ៣៣(ការរក្សាការសម្ងាត់)** និង មាត្រាទី៣៩ (ទោសពិន័យ)យើងខ្ញុំនឹងរក្សាទុករាល់ខ្លឹមសារចំលើយ និង ការសម្ងាត់ឯកជនរបស់លោកអ្នកយ៉ាងតឹងរឹងបំផុត។

※ 표지 부분은 조사원이 기입합니다.

| | | | |
|---|---|---|---|
| 주 소 | ______ 시 · 도 ______ 시 · 군 · 구 ______ 로 (길) ______ | | |
| | 공동주택명 ______ ______ 동 ______ 호 | | |
| 관리사항 | 행정구역 분류 코드 | 세대 번호 | 응답 가구원 번호 |
| | | | 0 1 |

| | | | |
|---|---|---|---|
| 가구원 성명 | | 조사표 종류 | ① 한국어<br>② 외국어(          ) |
| 가구당 조사표 부수 | 총 (    )부 중 ( 1 )부 | 지역조사본부 (지역센터명) | |
| 조사표 기입 방법 | ① 조사원 면접식<br>② 자기 기입식 | 조사원 성명 | |
| 응답 소요 시간 | ① 20분 이내   ③ 41분~50분<br>② 21분~30분   ④ 51분 이상 | 연 락 처 | |

여성가족부 한국통계진흥원 한국여성정책연구원 Korean Women's Development Institute

▶ កម្រងសំនួរនេះបំពេញដោយអ្នកដែលកើតមកមានសញ្ជាតិផ្សេងដូចជា ស្ត្រីរៀបការ ឬ អ្នកបានចូលសញ្ជាតិ(រួមទាំងអ្នកមានសញ្ជាតិពីរ)។
▶ ក្នុងករណី 'ជំរើសផ្សេង' សូមសរសេរខ្លឹមសារជាភាសាកូរ៉េក្នុង (          )។

# I ជីវតអាពាហ៍ពិពាហ៍ និង ទំនាក់ទំនងគ្រួសារ

## ស្ថានភាពអាពាហ៍ពិពាហ៍

**1** តើស្ថានភាពអាពាហ៍ពិពាហ៍របស់អ្នកស្ថិតក្នុងស្ថានភាពបែបណាក្នុងចំណោមចំណុចខាងក្រោមនេះ?

① នៅលីវ ⟶ សូមប្តូរទៅលេខ **18**
② បានរៀបការ (រួមទាំងការរស់នៅដោយ មិនបានចុះអ៊ីតាស៊ីវិល)⟶សូមប្តូរទៅលេខ **1-1**
③ ប្តីប្រពន្ធស្លាប់ ⟶ សូមប្តូរទៅលេខ **1-2**
④ លែងលះ •រស់នៅបែកគ្នា ⟶ សូមប្តូរទៅលេខ **1-3**

**1-1** តើសព្វថ្ងៃអ្នករស់នៅជាមួយប្តី ឬ ប្រពន្ធអ្នកទេ?

① បាទ/ចាស់ ② ទេ(ជួបគ្នាចុងសប្តាហ៍) ⟶ ឆ្លើយរួច សូមប្តូរទៅលេខ **2**

**1-2** តើទទួលមរណភាពពេលណា?

☐☐☐☐ ឆ្នាំ ⟶ ឆ្លើយរួច សូមប្តូរទៅលេខ **11**

**1-3** តើអ្នកលែងលះ ឬ រស់នៅបែកគ្នាតាំងពីពេលណា?

☐☐☐☐ ឆ្នាំ

**1-4** តើអ្វីជាមូលហេតុធំបំផុតជំរុញឲ្យអ្នកលែងលះ ឬ រស់នៅបែកគ្នាសូមជ្រើសរើសចម្លើយ ចម្បងតែ<u>មួយចម្លើយ</u>ប៉ុណ្ណោះ

① អំពើផិតក្បត់
② ចរិកមិនត្រូវគ្នា
③ វប្បធិខុសគ្នា
④ ជំលោះជាមួយគ្រួសារប្តីឬប្រពន្ធ
⑤ បញ្ហាសេដ្ឋកិច្ចគ្រួសារ
⑥ បញ្ហាកូន
⑦ ការរំលោភបំពាន អំពើហឹង្សា
⑧ ញៀនស្រា ញៀនល្បែង
⑨ ពិការភាពផ្នែនសតិស្មារតីធ្ងន់ធ្ងរ
⑩ ប្តីឬប្រពន្ធរត់ចេញពីផ្ទះ
⑪ ផ្សេងៗ(                    )

☞ សំនួរខាងក្រោមនេះ សំរាប់តែប្តី ឬ ប្រពន្ធដែលលែងលះ ឬ រស់នៅបែកគ្នា ហើយមានកូន អាយុក្រោម **18ឆ្នាំ(កើតក្រោយថ្ងៃទី 1សីហា 2002)** ឆ្លើយប៉ុណ្ណោះ។ ប្រសិនបើគ្មាន សូមប្តូរទៅលេខ **11**។

**1-5** ជាទូទៅតើនរណាជាអ្នកចិញ្ចឹមកូនច្រើនជាង?

① សាមីខ្លួន ⟶ សូមប្តូរទៅលេខ **1-5-1** ② ប្តីឬប្រពន្ធ ⟶ សូមប្តូរទៅលេខ **1-5-2** ③ ផ្សេង

**1-5-1** តើអ្នកទទួលប្រាក់សំរាប់ចិញ្ចឹមកូនពីប្តី ឬ ប្រពន្ធរបស់អ្នកយ៉ាងដូច្មេះ?

① ទទួលបានជាប្រចាំ
② ទទួលបានសរុបតែមួយលើក
③ ពីមុនបានទទួល តែឥឡូវមិនបានទទួលទេ
④ ពីមុនខ្ញុំមិនបានទទួលទេ តែពេលនេះចាប់ផ្តើមបានទទួលហើយ
⑤ ខ្ញុំមិនធ្លាប់បានទទួលទេ

▶▶ ឆ្លើយរួច សូមប្តូរទៅលេខ **11**

**1-5-2** ជាធម្មតា តើអ្នក**ទាក់ទង**ទៅកូនរបស់អ្នកដោយរបៀបណា?

① ជួបកូនជាប្រចាំ
② ជួបនៅពេលមានកិច្ចការពិសេស
③ (ទាក់ទងដោយសរសេរសំបុត្រ/អ៊ីមែល ឬ តាមទូរស័ព្ទ (មិនជួបផ្ទាល់ទេ)
④ (លឺដំណឹងតាមរយ:សាច់ញាតិនៃគ្រួសារទាំងពីរ (មិនទាក់ទងដោយផ្ទាល់ឡើយ)
⑤ មិនដឹងពត៌មាន ហើយមិនទាក់ទងជាមួយពួកគេទេ

ចំណាំ) ការរស់នៅបែកគ្នាគឺសំរាប់ទែអ្នកដែលរស់នៅបែបគ្នាដោយសារការបែកប្រាក់គ្រួសារប៉ុណ្ណោះ (លើកលែងប្តីប្រពន្ធជួបគ្នាចុងសប្តាហ៍)

▶▶ ឆ្លើយរួច សូមប្តូរទៅលេខ **11**

# ជីវិតជាប្ដីប្រពន្ធ

**2** តើអ្នកចំណាយពេលជាមធ្យមក្នុងមួយថ្ងៃរយៈប៉ុន្មាន ក្នុងការសន្ទនាជាមួយប្ដី ឬប្រពន្ធ? (រួមបញ្ចូលទាំងតាមរយៈទូរស័ព្ទ សារ Kakaotalk, SNS ឬ អ៊ីមែលជាដើម)

① មិនសន្ទនាគ្នាសោះ
② ក្រោម 30 នាទី
③ 30នាទី~1ម៉ោង
④ 1ម៉ោង~2ម៉ោង
⑤ 2ម៉ោងឡើងទៅ

**3** តើអ្នកពេញចិត្តក្នុងទំនាក់ទំនងជាមួយគ្រួសាររបស់អ្នកកម្រិតណា?

| ប្រភេទ | ពេញចិត្តណាស់ | ពេញចិត្តតិចតួច | ធម្មតា | មិនសូវពេញចិត្ត | មិនពេញចិត្ត | គ្មានចំលើយ |
|---|---|---|---|---|---|---|
| 1) ប្ដី ឬ ប្រពន្ធ | ① | ② | ③ | ④ | ⑤ | |
| 2) ឪពុកម្ដាយប្ដីឬប្រពន្ធ | ① | ② | ③ | ④ | ⑤ | ⓪ (គ្មានឪពុក / ម្ដាយ) |
| 3) ឪពុកម្ដាយរបស់ខ្ញុំ | ① | ② | ③ | ④ | ⑤ | ⓪ (គ្មានឪពុក / ម្ដាយ) |

**4** នៅក្នុងគ្រួសារអ្នក តើអ្នកណាជាអ្នកធ្វើសកម្មភាពដូចខាងក្រោម?

| ប្រភេទ | ខ្ញុំជានិច្ច | ភាគច្រើនគឺខ្ញុំ | ជាមួយគ្នា | ភាគច្រើនប្ដីឬប្រពន្ធ | ប្ដីឬប្រពន្ធជានិច្ច | អ្នកផ្សេងក្នុងគ្រួសារ | គ្មានចំលើយ |
|---|---|---|---|---|---|---|---|
| 1) ការងារផ្ទះ-ពលកម្មក្នុងផ្ទះ | ① | ② | ③ | ④ | ⑤ | ⑥ | |
| 2) មើលថែកូន | ① | ② | ③ | ④ | ⑤ | ⑥ | ⓪ (គ្មានកូន) |
| 3) មើលថែផ្សេងក្រៅពីកូន | ① | ② | ③ | ④ | ⑤ | ⑥ | ⓪ (គ្មានគ្រួសារផ្សេងក្រៅពីកូន) |
| 4) គ្រប់គ្រប់ទ្រព្យសម្បត្តិដូចជាការសន្សំប្រាក់ ការខ្ចីប្រាក់ | ① | ② | ③ | ④ | ⑤ | ⑥ | |

**5** ក្នុងរយៈពេល1ឆ្នាំកន្លងមកនេះ(ថ្ងៃទី1 សីហា 2020 ~ ដល់ថ្ងៃទី31 កក្កដា 2021) តើអ្នកមានអារម្មណ៍ថាវប្បធម៌ខុសគ្នាជាមួយប្ដី ឬ ប្រពន្ធអ្នកញឹកញាប់ប៉ុណ្ណា?

① មិនមានសោះ
② មានអារម្មណ៍ម្ដងម្កាល
③ មានអារម្មណ៍ញឹកញាប់
④ មានអារម្មណ៍ញឹកញាប់ណាស់

**5-1** បើមានគម្លាតវប្បធម៌ តើអ្នកគិតថាបញ្ហាណាខ្លាំងជាងគេ? សូមជ្រើសរើសចំលើយ? ចំនួន ៣ ☐, ☐, ☐

① ទម្លាប់ទទួលទានអាហារ
② ទម្លាប់ក្នុងការស្លៀកពាក់
③ របៀបចិញ្ចឹម និង បង្រៀនកូន
④ របៀបបែងចែកកិច្ចការផ្ទះ
⑤ របៀបថែមទាំឪពុកម្ដាយ
⑥ ពិធីបុណ្យផ្សេងក្នុងគ្រួសារ
⑦ ការយល់ឃើញទាក់ទងនឹងសាសនា
⑧ ភាពខុសគ្នាទាក់ទងនឹងសេដ្ឋកិច្ចគ្រួសារដូចជា កាសន្សំ និង ការចំណាយ
⑨ របៀបក្នុងការប្រាស្រ័យទាក់ទងគ្នា
⑩ ផ្សេងៗ( )

**6** ក្នុងរយៈពេល1ឆ្នាំកន្លងមកនេះ(ថ្ងៃទី1 សីហា 2020 ~ ដល់ថ្ងៃទី31 កក្កដា 2021) តើអ្នកធ្លាប់ឈ្លោះគ្នាជាមួយប្តីឬប្រពន្ធអ្នកទេ?

① មាន → សូមប្តូរទៅលេខ **6-1**　　② អត់មានទេ → សូមប្តូរទៅលេខ **7**

**6-1** ក្នុងរយៈពេល1ឆ្នាំកន្លងមកនេះ(ថ្ងៃទី1 សីហា 2020 ~ ដល់ថ្ងៃទី31 កក្កដា 2021) តើអ្នកឈ្លោះគ្នាដោយសារមូលហេតុអ្វីខ្លាំងជាងគេ? សូមជ្រើសរើស**ចំលើយពីរដែលសំខាន់បំផុត**។

☐ (ទី1)　☐ (ទី2)

① ចរិត គំនិត និង គុណតំលៃរបស់ប្តី ឬ ប្រពន្ធ
② បញ្ហាចិញ្ចឹមកូន និង ការអប់រំ
③ បញ្ហាសេដ្ឋកិច្ចដូចជាប្រាក់ចាយវាយប្រចាំថ្ងៃ
④ ផលវិបាកក្នុងការប្រើប្រាស់ភាសា
⑤ វប្បធម៌ និង សាសនាខុសគ្នា
⑥ ទំលាប់ប្រចាំថ្ងៃរបស់ប្តីឬប្រពន្ធ(ផឹកស្រា, ត្រលប់មកផ្ទះយប់ជ្រៅជាដើម)
⑦ បញ្ហាទាក់ទងនឹងគ្រួសារប្តីឬប្រពន្ធ
⑧ បញ្ហាទាក់ទងនឹងគ្រួសារខ្ញុំ
⑨ ជីវិតផ្លូវភេទរបស់ប្តីឬប្រពន្ធ
⑩ ពាក្យសំដីជេរប្រមាថឬអំពើហឹង្សារបស់ប្តីឬប្រពន្ធ
⑪ ផ្សេងៗ(　　　　　　　　)

---

**7** នៅពេលមានជំលោះកើតឡើងរវាងអ្នក និង ប្តីឬប្រពន្ធអ្នក ជាទូទៅអ្នកធ្វើដូចម្តេច?
សូមជ្រើសរើស**ចំលើយពីរ**តាមលំដាប់លំដោយនៃវិធីសាស្រ្តដែលអ្នក**ប្រើប្រាស់ញឹកញាប់ជាងគេបំផុត**។

☐ (ទី1)　☐ (ទី2)

① អត់ធ្មត់
② ស្វែងរកវិធីដោះស្រាយដោយខ្លួនឯង
③ ធ្វើកិច្ចការផ្សេងដើម្បីបំភ្លេច(ហ្សប់ភីង ហាត់កីឡា ផឹកស្រា សកម្មភាពសាសនាជាដើម)
④ ស្វែងរកជំនួយ
⑤ និយាយទៅកាន់អ្នកនៅជុំវិញ(មិត្តភក្តិ,សាច់ញាតិ ជាដើម)
⑥ ប្រឹក្សាយោបល់ជាមួយអ្នកជំនាញ
⑦ ផ្សេងៗ(　　　　　　　　)

## ជំនួប និង អាពាហ៍ពិពាហ៍

**8** តើអ្នកចាប់ផ្តើមរស់នៅជាមួយប្តីឬប្រពន្ធអ្នកតាំងពីពេលណា?

※ សូមសរសេរឆ្នាំដែលអ្នកចាប់ផ្តើមរស់នៅជាមួយគ្នាដោយមិនគិតពីពេលរៀបការ ឬ ពេលរាយការណ៍អាពាហ៍ពិពាហ៍

☐☐☐☐ ឆ្នាំ

---

**9** តើនេះជា**ការរៀបការដំបូង**របស់អ្នក? ឬ **ការរៀបការម្តងទៀត**របស់អ្នក?

① រៀបការដំបូង(រៀបការលើកទី១)
② រៀបការម្តងទៀត

---

**10** តើអ្នកបានជួបប្តី ឬ ប្រពន្ធអ្នកយ៉ាងដូចម្តេច?

① ដោយការណែនាំរបស់គ្រួសារ ឬ សាច់ញាតិ
② ដោយការណែនាំរបស់មិត្តភក្តិ ឬ មិត្តរួមការងារ
③ តាមរយៈក្រុមហ៊ុនអាពាហ៍ពិពាហ៍(ឬ ឈ្មួញកណ្តាល)
④ តាមរយៈស្ថាប័នសាសនា
⑤ ដោយខ្លួនឯង
⑥ ផ្សេងៗ(　　　　　　　　)

## II ការចិញ្ចឹមកូន

☞ សំនួរខាងក្រោមសំរាប់តែអ្នកមានកូនក្រោមអាយុ24ឆ្នាំឆ្លើយ។
ករណីគ្មានកូន ឬ មានកូនក្រោមអាយុ25ឆ្នាំ (កើតមុនថ្ងៃទី. 31 កក្កដា 1996) សូមប្តូរទៅលេខ 18

### តួនាទីឪពុកម្តាយ និង ការចិញ្ចឹមកូន

**11** តើអ្នកគឺយ៉ាងដូចម្តេចអំពីខ្លួនឯងក្នុងនាមជាឪពុកម្តាយ?

| ខ្លឹមសារ | អញ្ចឹងខ្លាំង | ភាគច្រើនអញ្ចឹង | ធម្មតា | មិនសូវអញ្ចឹងទេ | មិនអញ្ចឹងសោះ |
|---|---|---|---|---|---|
| 1) ខ្ញុំជាមនុស្សពូកែដោះស្រាយបញ្ហាដែលកើតមានជាមួយកូន | ① | ② | ③ | ④ | ⑤ |
| 2) ខ្ញុំដឹងវិធីនិងមានចំណេះដឹងដែលត្រូវការចាំបាច់ដើម្បីក្លាយជាឪពុកម្តាយល្អ | ① | ② | ③ | ④ | ⑤ |
| 3) ខ្ញុំដឹងជាងនរណាទាំងអស់ថាតើកូនរបស់ខ្ញុំកំពុងតែលំបាកដោយសារមូលហេតុអ្វី | ① | ② | ③ | ④ | ⑤ |

**12** តើអ្នកពេញចិត្តក្នុងទំនាក់ទំនងជាមួយកូនរបស់អ្នកប៉ុណ្ណា?

① ពេញចិត្តណាស់
② ពេញចិត្តតិចតួច
③ ធម្មតា
④ មិនសូវពេញចិត្តទេ
⑤ មិនពេញចិត្តសោះ

**13** តើអ្នកធ្លាប់អញ្ជើញឪពុកម្តាយឬបងប្អូនដែលនៅស្រុកកំណើតរបស់អ្នកមកប្រទេសកូរ៉េ ដើម្បីមើលថែ ឬចិញ្ចឹមកូនអ្នកដែរឬទេបើមានចំណុចណាខ្លះ សូមជ្រើសរើស? **ទាំងអស់។**

① ខ្ញុំធ្លាប់អញ្ជើញឪពុកម្តាយបងប្អូនពីស្រុកកំណើតរបស់ខ្ញុំមកកូរ៉េ
② ខ្ញុំធ្លាប់បញ្ជូនកូនរបស់ខ្ញុំទៅឪពុកម្តាយបងប្អូននៅប្រទេសខ្ញុំ
③ មិនមានចម្លើយ

☞ សំនួរខាងក្រោមនេះ សំរាប់តែអ្នកមានកូនអាយុក្រោម 5ឆ្នាំ(កើតក្រោយថ្ងៃទី 1 សីហា 2015) ឆ្លើយប៉ុណ្ណោះ។ ប្រសិនបើគ្មាន សូមប្តូរទៅលេខ 16 ។

**14** ក្នុងនាមអ្នកជាឪពុកម្តាយដែលមានកូនអាយុក្រោម 5ឆ្នាំតើចំនុចមួយណាដែលលំបាកជាងគេសម្រាប់អ្នកសូមជ្រើសរើស**ចំលើយមួយ**។

① គំនិតខុសគ្នាជាមួយគ្រួសារឬប្តីប្រពន្ធទាក់ទងនឹងការចិញ្ចឹមកូន
② ពិបាកក្នុងការស្វែងរកមនុស្សមើលថែកូននៅពេលដែលខ្ញុំរវល់ឬមានជំងឺ
③ ពិបាកក្នុងការបង្រៀនភាសាកូរ៉េដោយផ្ទាល់ទៅកូន
④ មិនសូវស្គាល់ច្បាស់អំពីកន្លែងមើលថែកុមារ សាលាមត្តេយ្យ ឬសាលារៀន(នៅប្រទេសកូរ៉េ)
⑤ អ្នកនៅជុំវិញមិនឲ្យតម្លៃលើគំនិតរបស់ខ្ញុំទាក់ទងនឹងការចិញ្ចឹមកូន
⑥ ផ្សេងៗ( )
⑦ មិនមានផលវិបាកទេ

**15** តើប្តីប្រពន្ធរបស់អ្នកបែងចែកការងារពាក់ព័ន្ធនឹងការមើលថែកូនក្រោមអាយុ 5 ឆ្នាំដែលមិនទាន់ចូលរៀនយ៉ាងដូចម្តេច?

| ខ្លឹមសារ | ខ្ញុំជានិច្ច | ភាគច្រើនគឺខ្ញុំ | ជាមួយគ្នា | ភាគច្រើនប្តីឬប្រពន្ធ | ប្តីឬប្រពន្ធជានិច្ច | មិនមានប្តីឬប្រពន្ធ |
|---|---|---|---|---|---|---|
| 1) សកម្មភាពពាក់ព័ន្ធនឹងការស្លៀកពាក់ អាហារ និងកន្លែងរស់នៅ(បញ្ចុកបាយ ស្លៀកពាក់ ឲ្យគេង និងសម្អាតខ្លួន) | ① | ② | ③ | ④ | ⑤ | ⓞ |
| 2) សកម្មភាពនៅពេលលេង (លេងជាមួយ អានសៀវភៅឱ្យស្តាប់) | ① | ② | ③ | ④ | ⑤ | ⓞ |

☞ សំនួរខាងក្រោមនេះ សំរាប់តែអ្នកមានកូនអាយុចាប់ពី 6ឆ្នាំ ដល់ 24ឆ្នាំ (ថ្ងៃទី 1 សីហា 1996 ~ 31 កក្កដា 2015) ឆ្លើយប៉ុណ្ណោះ។ ប្រសិនបើគ្មាន សូមប្តូរទៅលេខ 18 ។

**16** ជាធម្មតាតាអ្វីទៅជា**ផលវិបាកខ្លាំងបំផុត**ដែលអ្នកមានក្នុងនាមជាឪពុកម្តាយដែល**ចិញ្ចឹមកូន**។ សូមជ្រើសរើសចម្លើយ**ចំនួនពីរតាមលំដាប់លំដោយ**។

[ ] (ទី1) [ ] (ទី2)

① បន្ទុកនៃការចំណាយលើកូនដូចជាថ្លៃសិក្សានិងថ្លៃចាយវាយ

② កង្វះព័ត៌មានពាក់ព័ន្ធនឹងការសិក្សាការប្តូរសាលារៀននិងផ្លូវអនាគតរបស់កូន

③ ពិបាកក្នុងការគ្រប់គ្រងការជួយបង្រៀននិងការសិក្សារបស់កូន

④ ខ្វះការសន្ទនាជាមួយកូន

⑤ ពិបាកក្នុងការចូលរួមសកម្មភាពរបស់អាណាព្យាបាលដូចជាសមាគមអាណាព្យាបាលសិស្ស សកម្មភាពបម្រើស្ម័គ្រចិត្តជាដើម

⑥ មានទំនាស់ជាមួយកូនដោយសារការលេងហ្គេមការប្រើប្រាស់ទូរស័ព្ទដៃនិងអ៊ីនធឺណិត

⑦ បញ្ហាពាក់ព័ន្ធនឹងការផឹកស្រា ការជក់បារី ការរត់ចេញពីផ្ទះរបស់កូន

⑧ ផ្សេងៗ( )

⓪ មិនមានផលវិបាកទេ

---

**17** តើអ្នកបានជួបនឹង**បទពិសោធន៍**បែបណាខ្លះទាក់ទងនឹង**ការចូលរៀនតាមអនឡាញ**របស់កូនអ្នកក្នុងសម័យកូវិដ-19? សូមឆ្លើយនឹងសំណួរខាងក្រោម។

| ខ្លឹមសារ | អញ្ចឹងខ្លាំង | ភាគច្រើនអញ្ចឹង | ធម្មតា | មិនសូវអញ្ចឹងទេ | មិនអញ្ចឹងសោះ |
|---|---|---|---|---|---|
| 1) រងបន្ទុកក្នុងការជាវឧបករណ៍សម្រាប់ការរៀនអនឡាញ | ① | ② | ③ | ④ | ⑤ |
| 2) ខ្ញុំជួបផលវិបាកដោយសារមិនចេះពីរបៀបភ្ជាប់កម្មវិធីពាក់ព័ន្ធនឹងការរៀនអនឡាញ។ | ① | ② | ③ | ④ | ⑤ |
| 3) ព្រួយបារម្ភខ្លាចកូនរៀនមិនទាន់គេដោយសារការចូលរៀនតាមអនឡាញ | ① | ② | ③ | ④ | ⑤ |
| 4) បារម្ភព្រោះគិតថាកូនលេងហ្គេមអ៊ីនធើនែត ឬ ហ្គេមទូរស័ព្ទ។ | ① | ② | ③ | ④ | ⑤ |

## ការសម្របក្នុងជីវិតរស់នៅក្នុងប្រទេសកូរ៉េ

**18** តើសមត្ថភាពភាសាកូរ៉េរបស់អ្នកមានកម្រិតត្រឹមណាដែរ?

| ខ្លឹមសារ | ពូកែខ្លាំងណាស់ | ពូកែតិចតួច | ធម្មតា | មិនសូវពូកែទេ | មិនចេះសោះ |
|---|---|---|---|---|---|
| 1) ការនិយាយ | ① | ② | ③ | ④ | ⑤ |
| 2) ការស្តាប់ | ① | ② | ③ | ④ | ⑤ |
| 3) ការអាន | ① | ② | ③ | ④ | ⑤ |
| 4) ការសរសេរ | ① | ② | ③ | ④ | ⑤ |

**19** តើអ្នកធ្លាប់ប្រលងសមត្ថភាពភាសាកូរ៉េ(TOPIK)ដែរឬទេ?

① ធ្លាប់ ⟶ សូមប្តូរទៅលេខ **19-1**　　② មិនធ្លាប់ទេ ⟶ សូមប្តូរទៅលេខ **20**

**19-1** តើលទ្ធផលប្រឡងរបស់អ្នកបានកម្រិតប៉ុន្មាន?

① កម្រិត 1
② កម្រិត 2
③ កម្រិត 3
④ កម្រិត 4
⑤ កម្រិត 5
⑥ កម្រិត 6
⓪ មិនមានកម្រិតទេ

**20** តើមួយឆ្នាំកន្លងមកនេះ(ថ្ងៃទី1 សីហា 2020 ~ ដល់ថ្ងៃទី31 កក្កដា 2021) អ្នកជួបបញ្ហាលំបាកអ្វីខ្លះក្នុងកំឡុងពេលរស់នៅប្រទេសកូរ៉េ? សូមជ្រើសរើសចម្លើយចំនួន 3 នៅក្នុងចំណោមចម្លើយឧទាហរណ៍ខាងក្រោម

① ភាពឯកោ
② ជំលោះជាមួយគ្រួសារ
③ ការចិញ្ចឹម និង ការអប់រំកូន
④ ការប្រើប្រាស់ស្ថាប័នសាធារណៈ(សាលាសង្កាត់, មជ្ឈមណ្ឌលរដ្ឋបាលនិងសុខុមាលភាព) ឬ ការប្រើប្រាស់ធនាគារ
⑤ ផលវិបាកផ្នែកសេដ្ឋកិច្ច
⑥ បញ្ហាភាសា
⑦ ភាពខុសគ្នានៃវប្បធម៌ដូចជារបៀបក្នុងការរស់នៅទម្លាប់នឹងអាហារជាដើម
⑧ ការរើសអើង
⑨ ការសេបគប់ជាមួយមិត្តភ័ក្រឬអ្នកជិតខាង
⑩ ផ្សេងៗ(　　　　　　　　　　　　　　)
⑪ មិនមានផលវិបាកទេ

## 21 តើអ្នកធ្លាប់ទទួលជំនួយពីអ្នកណាផ្សេងក្រៅពីគ្រួសារនៅក្នុងប្រទេសកូរ៉េក្នុងករណីដូចខាងក្រោមដែរទេ?

| ខ្លឹមសារ | មាន(សូមជ្រើសរើស**ទាំងអស់**) | | | អត់មាន | មិនមានចម្លើយ |
|---|---|---|---|---|---|
| | ជនជាតិខ្មែរ | ជនជាតិកូរ៉េ | ជនបរទេស | | |
| 1) អ្នកដែលអាចពិភាក្សាបាននៅពេលមានផលវិបាកផ្ទាល់ខ្លួន ឬនៅក្នុងផ្ទះ | ① | ② | ③ | ④ | |
| 2) អ្នកដែលអាចពិភាក្សាពាក់ព័ន្ធនិងកន្លែងការងារ | ① | ② | ③ | ④ | ⓞ |
| 3) អ្នកដែលអាចពិភាក្សាពាក់ព័ន្ធនឹងការអប់រំកូន | ① | ② | ③ | ④ | ⓞ ( គ្មានកូន ) |
| 4) អ្នកដែលធ្វើសកម្មភាពនៅពេលទំនេរឬមានចំណង់ចំណូលចិត្តដូចគ្នា | ① | ② | ③ | ④ | |
| 5) អ្នកដែលអាចជួយអ្នកនៅពេលអ្នកមិនស្រួលខ្លួន | ① | ② | ③ | ④ | |
| 6) អ្នកដែលជួយមើលកូននៅក្នុងស្ថានភាពបន្ទាន់ដូចជាស្ថានភាពកូវីដ-19 | ① | ② | ③ | ④ | ⓞ ( មិនមានកូនអាយុក្រោម9ឆ្នាំ ) |

## 22 ក្នុងពេលមួយឆ្នាំនេះ(ថ្ងៃទី1 សីហា 2020 ~ ដល់ថ្ងៃទី31 កក្កដា 2021) តើអ្នកធ្លាប់ចូលរួមក្នុងការជួបជុំឬសកម្មភាពណាដែរឬទេ? ឬតើអ្នកមានបំណងចង់ចូលរួមការជួបជុំដូចខាងក្រោមនៅពេលខាងមុខដែរឬទេ?

| ខ្លឹមសារ | 22-1 ធ្លាប់ចូលរួម | | | 22-1 ចង់ចូលរួមពេលខាងមុខ | | |
|---|---|---|---|---|---|---|
| | ធ្លាប់ | មិនធ្លាប់ | មិនមានចម្លើយ | ធ្លាប់ | មិនធ្លាប់ | មិនមានចម្លើយ |
| 1) ការជួបជុំអាណាព្យាបាលសិស្ស | ① | ② | ⓞ (មិនមានកូនរៀននៅសាលាបឋម អនុវិទ្យា ឬ វិទ្យាល័យទេ) | ① | ② | ⓞ (មិនមានកូនរៀននៅសាលាបឋម អនុវិទ្យា ឬ វិទ្យាល័យទេ) |
| 2) ការជួបជុំមិត្តភក្តិមកពីប្រទេសដូចគ្នា | ① | ② | | ① | ② | |
| 3) ការជួបជុំប្រជាជននៅក្នុងភូមិ (សមាគមម្តាយកូន បុណ្យភូមិ ការប្រកួតកីឡាជាដើម | ① | ② | | ① | ② | |
| 4) សកម្មភាពសាសនា | ① | ② | | ① | ② | |
| 5) សកម្មភាពសហគមន៍សង្គមស៊ីវិល (សមាគមគាំពារជនចំណាកស្រុក សមាគមបរិស្ថានសមាគមស្ត្រីជាដើម) | ① | ② | | ① | ② | |
| 6) សកម្មភាពនយោបាយ សហជីពកម្មករជាដើម | ① | ② | | ① | ② | |

## 23 តើអ្នកមានផលវិបាកនៅពេលចូលរួមការជួបជុំឬសកម្មភាពដែរឬទេ? ប្រសិនបើមានសូមជ្រើសរើសចម្លើយត្រឹមចំនួន 3។

① មិនពូកែនិយាយភាសាកូរ៉េ
② ការបដិសេធពីប្តីឬប្រពន្ធឬគ្រួសារ
③ មានអារម្មណ៍ថាអ្នកដទៃមិនចូលចិត្តខ្ញុំ
④ ត្រូវមើលថៃគ្រួសារ
⑤ ត្រូវធ្វើការងារ
⑥ អត់មានអ្នកទៅចូលរួមការជួបជុំជាមួយគ្នា
⑦ ខ្វះព័ត៌មានទាក់ទងនឹងការជួបជុំឬសកម្មភាព
⑧ មិនមានការជួបជុំណាដែលចង់ចូលរួម
⑨ ផ្សេងៗ( )
ⓞ មិនមានផលវិបាក

## បទពិសោធន៍ពាក់ព័ន្ធនឹងការរើសអើង

**24** តើអ្នកគិតថាការស្អប់ ឬ ការរើសអើងចំពោះជនបរទេស ឬ ជនចំណាកស្រុកកាន់តែមានភាពធ្ងន់ធ្ងរឡើងក្នុងសង្គមកូរ៉េដោយសារ covid-19 ដែរទេ?

① គិតអញ្ចឹងខ្លាំងណាស់
② គិតអញ្ចឹងតិចតួច
③ ធម្មតា
④ មិនសូវគិតអញ្ចឹងទេ
⑤ មិនគិតអញ្ចឹងសោះ

---

**25** ក្នុងពេលមួយឆ្នាំនេះ(ថ្ងៃទី1 សីហា 2020 ~ ដល់ថ្ងៃទី31 កក្កដា 2021)តើធ្លាប់មានគេរើសអើងដោយសារអ្នកជាជនបរទេសរស់នៅក្នុងប្រទេសកូរ៉េដែរឬទេ?

① មាន
② មិនមាន → សូមប្តូរទៅលេខ **26**

**25-1** តើអ្នកទទួលការរើសអើងកម្រិតណានៅទីកន្លែងដូចខាងក្រោម?

| ខ្លឹមសារ | ទទួលការរើសអើងខ្លាំងណាស់ | ទទួលការរើសអើយញឹកញាប់ | ទទួលការរើសអើងម្តងម្កាល | មិនទទួលការរើសអើងសោះ | មិនមានបទពិសោធន៍ប្រើប្រាស់ទេ |
|---|---|---|---|---|---|
| 1) នៅតាមដងផ្លូវឬក្នុងភូមិ | ① | ② | ③ | ④ | |
| 2) នៅក្នុងហាង ភោជនីយដ្ឋាន ឬធនាគារ | ① | ② | ③ | ④ | ⓪ |
| 3) ស្ថាប័នសាធារណ: (សាលាសង្កាត់,មជ្ឈមណ្ឌលរដ្ឋបាល និង សុខុមាលភាព) | ① | ② | ③ | ④ | ⓪ |
| 4) ក្រុមហ៊ុន/កន្លែងការងារ | ① | ② | ③ | ④ | ⓪ |
| 5) សាលារៀន ឬកន្លែងមើលថែកូន | ① | ② | ③ | ④ | ⓪ |
| 6) ផ្ទះ(ពីគ្រួសារ ឬសាច់ញាតិ) | ① | ② | ③ | ④ | |

**25-2** នៅពេលអ្នករងការរើសអើង តើអ្នកបាន**ឆ្លើយតបយ៉ាងដូចម្តេច?** សូមជ្រើសរើសចម្លើយទាំងអស់ដែលត្រូវនឹងអ្នក។

① សុំឲ្យភាគីម្ខាងទៀតសុំទោសខ្ញុំ
② ពិភាក្សាជាមួយគ្រួសារឬមិត្តភក្តិ
③ សាកសួរទៅកាន់ស្ថាប័ន ឬមជ្ឈមណ្ឌលប្រឹក្សាយោបល់
④ រាយការណ៍ទៅកាន់ស្ថាប័នពាក់ព័ន្ធនឹងការរាយការណ៍ស្តីពីការរើសអើង
⑤ បង្ហោះខ្លឹមសារចូលទៅក្នុងអ៊ីនធឺណិតកាហ្វេនិងបណ្តាញសង្គម
⑥ អត់ធ្មត់
⑦ ផ្សេងៗ(                                        )

# បទពិសោធន៍ និងការទាមទារចូលរួមសេវាកម្ម

**26** មកដល់ពេលនេះឬ ក្នុងពេលមួយឆ្នាំនេះ(ថ្ងៃទី1 សីហា 2020 ~ ដល់ថ្ងៃទី31 កក្កដា 2021)តើអ្នកធ្លាប់ទទួលការអប់រំ ឬសេវាកម្មគាំពារ ដូចខាងក្រោមដែរឬទេ? តើអ្នកគិតថាការអប់រំ និងការគាំពារខាងក្រោមចាំបាច់ប៉ុណ្ណា?

| ខ្លឹមសារ | 26-1 បទពិសោធន៍ប្រើប្រាស់សេវាកម្ម | | | 26-2 តម្រូវការ | | | | |
|---|---|---|---|---|---|---|---|---|
| | ក្នុងរយៈពេល1ឆ្នាំចុងក្រោយ ខ្ញុំធ្លាប់ប្រើប្រាស់ | ត្រូវការខ្លាំង | ត្រូវការខ្លាំង | ត្រូវការខ្លាំង | ត្រូវការខ្លាំង | ត្រូវការខ្លាំង | មិនសូវត្រូវការ | មិនត្រូវការសោះ |
| 1) ការអប់រំដើម្បីត្រៀមសម្រាប់ជីវិតរស់នៅក្នុងប្រទេសកូរ៉េមុនពេលចូលប្រទេសកូរ៉េ(ភាសាកូរ៉េជាដើម) | ① | ② | ③ | ① | ② | ③ | ④ | ⑤ |
| 2) ការអប់រំតាមរយៈការមកទស្សនកិច្ចផ្ទះផ្ទាល់ (ភាសាកូរ៉េ ការអប់រំមាតាបិតា ជីវិតរស់នៅ និងការសិក្សារបស់កូនជាដើម) | ① | ② | ③ | ① | ② | ③ | ④ | ⑤ |
| 3) ការអប់រំដើម្បីសម្របក្នុងសង្គមកូរ៉េនិងភាសាកូរ៉េ | ① | ② | ③ | ① | ② | ③ | ④ | ⑤ |
| 4) គាំពារសេវាកម្មបកប្រែ | ① | ② | ③ | ① | ② | ③ | ④ | ⑤ |
| 5) គាំពារសម្រាប់ការមានផ្ទៃពោះនិងការសម្រាលកូន | ① | ② | ③ | ① | ② | ③ | ④ | ⑤ |
| 6) ការអប់រំឪពុកម្ដាយ | ① | ② | ③ | ① | ② | ③ | ④ | ⑤ |
| 7) គាំពារការរីកចម្រើនភាសារបស់កូន ការអប់រំភាសាទី 2 | ① | ② | ③ | ① | ② | ③ | ④ | ⑤ |
| 8) គាំពារជីវិតរស់នៅនិងការសិក្សារបស់កូន | ① | ② | ③ | ① | ② | ③ | ④ | ⑤ |
| 9) គាំពារសកម្មភាពក្នុងសង្គម(ការជួបជុំផ្ទាល់ ជាដើម) | ① | ② | ③ | ① | ② | ③ | ④ | ⑤ |
| 10) ការប្រឹក្សាយោបល់គ្រប់ប្រភេទ (ប្រឹក្សាច្បាប់ទាក់ទងនឹងទំនាក់ទំនងគ្រួសារ ទិដ្ឋការ និង ការទទួលសញ្ជាតិ) | ① | ② | ③ | ① | ② | ③ | ④ | ⑤ |
| 11) គាំពារសម្រាប់ការផ្ទេរសាលារៀននៅក្នុងប្រទេសកូរ៉េ (ការប្រលងស្វ័យរិនជាដើម) | ① | ② | ③ | ① | ② | ③ | ④ | ⑤ |
| 12) ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ① | ② | ③ | ① | ② | ③ | ④ | ⑤ |
| 13) ណែនាំកន្លែងធ្វើការងារ | ① | ② | ③ | ① | ② | ③ | ④ | ⑤ |
| 14) គាំពារការបង្កើតអាជីវកម្ម | ① | ② | ③ | ① | ② | ③ | ④ | ⑤ |

**27** តើអ្នកស្គាល់កន្លែងមួយចំនួនដូចខាងក្រោមទេ? បើអ្នកស្គាល់ តើអ្នកធ្លាប់ប្រើប្រាស់ដែរឬទេ? មកដល់ពេលនេះ ឬមួយឆ្នាំចុងក្រោយ(ថ្ងៃទី1 សីហា 2020 ~ ដល់ថ្ងៃទី31 កក្កដា 2021)នេះ?

| ខ្លឹមសារ | ស្គាល់ | | | មិនស្គាល់ |
|---|---|---|---|---|
| | ធ្លាប់ប្រើប្រាស់ក្នុងរយៈពេល1ឆ្នាំចុងក្រោយ | ធ្លាប់ប្រើប្រាស់ដែរ តែ1ឆ្នាំចុងក្រោយនេះ អត់បានប្រើប្រាស់ទេ | មិនធ្លាប់ប្រើប្រាស់ម្ដងសោះ | |
| 1) មជ្ឈមណ្ឌលគាំពារគ្រួសារពហុវប្បធម៌/មជ្ឈមណ្ឌលគាំពារសុខភាពគ្រួសារពហុវប្បធម៌ | ① | ② | ③ | ④ |
| 2) មជ្ឈមណ្ឌលខលទូរសព្ទថានូរី(1577-1366) | ① | ② | ③ | ④ |
| 3) សាលាសង្កាត់, មជ្ឈមណ្ឌលរដ្ឋបាលនិងសុខុមាលភាព | ① | ② | ③ | ④ |
| 4) មជ្ឈមណ្ឌលធ្វើការថ្មីសម្រាប់ស្ត្រី មជ្ឈមណ្ឌលស្ត្រីគាំពារដោយរដ្ឋាភិបាល(មជ្ឈមណ្ឌលសមាគមស្ត្រី មជ្ឈមណ្ឌលរីកចម្រើនសម្រាប់ស្ត្រី ជាដើម) | ① | ② | ③ | ④ |
| 5) មជ្ឈមណ្ឌលការងារ មជ្ឈមណ្ឌលការងារនិងសុខមាលភាព plus | ① | ② | ③ | ④ |
| 6) ការិយាល័យសុខមាលភាពសង្គម | ① | ② | ③ | ④ |
| 7) សហគមន៍គាំពារជនបរទេសផ្សេងៗ (មជ្ឈមណ្ឌលផ្លាស់ប្ដូរអន្តរជាតិ សហគមន៍សាសនា មជ្ឈមណ្ឌលការងារ មជ្ឈមណ្ឌលប្រឹក្សាយោបល់ជាដើម) | ① | ② | ③ | ④ |

## IV សកម្មភាពសេដ្ឋកិច្ច

### បទពិសោធន៍ធ្វើការងារនៅក្នុងប្រទេសកូរ៉េ

**28** តើអ្នកធ្លាប់ធ្វើការនៅក្នុងប្រទេសកូរ៉េដែលទេ? បើធ្លាប់ តើអ្នកបានចាប់ផ្តើម? **ធ្វើការងារនៅប្រទេសកូរ៉េលើកដំបូងនៅពេល(ឆ្នាំ)ណា?**

| អត្ថន័យនៃពាក្យ 'ធ្វើការ' |
|---|
| ប្រសិនបើអ្នកមានចំណុចណាដូចនឹង**ករណីតែមួយក៏ដោយ**នៅខាងក្រោមមានន័យថាអ្នកបានធ្វើការងារហើយ។<br>1) ធ្វើការ**លើសពីមួយម៉ោង**ដើម្បីរកលុយ<br>2) **ធ្វើការលើសពី 18 ម៉ោង**នៅក្នុងហាងពេងចក្រកសិដ្ឋានដែលជារបស់គ្រួសារដោយមិនទទួលប្រាក់កម្រៃ<br>3) ធ្វើការងារលើសពីមួយម៉ោងដែលមានប្រាក់ចំណូលដូចជាការងារបន្ថែមឬការងារក្រៅម៉ោង |

① មាន ⟶ ឆ្នាំដែលចាប់ផ្តើមធ្វើការនៅដំបូងនៅក្នុងប្រទេសកូរ៉េ ☐☐☐☐ ឆ្នាំ

② គ្មាន ⟶ សូមប្តូរទៅលេខ 36

### ស្ថានភាពនៃសកម្មភាពសេដ្ឋកិច្ច

**29** តើអ្នកមានបាន**ធ្វើការលើសពីមួយម៉ោង**ក្នុងរយៈពេលមួយសប្តាហ៍(ថ្ងៃទី25 ដល់ថ្ងៃទី31 កក្កដា 2021) ចុងក្រោយនេះដើម្បីរកប្រាក់ដែរឬទេ?

① មាន ⟶ សូមប្តូរទៅលេខ 30

② អត់មានទេ

**29-1** ក្នុងរយៈពេលមួយសប្តាហ៍(ថ្ងៃទី25 ដល់ថ្ងៃទី31 កក្កដា 2021) ចុងក្រោយនេះតើអ្នកបានធ្វើការនៅក្រុមហ៊ុន ឬកសិដ្ឋានរបស់គ្រួសារដែលរស់នៅជាមួយគ្នាលើសពីមួយម៉ោងដោយមិនទទួលប្រាក់កម្រៃដែរទេ?

① ខ្ញុំមិនបានធ្វើការទេ

② ខ្ញុំបានធ្វើការក្រោម 18 ម៉ោង

③ ខ្ញុំបានធ្វើការនៅលើសពី 18 ម៉ោង ⟶ សូមប្តូរទៅលេខ 30

**29-2** ក្នុងរយៈពេលមួយសប្តាហ៍(ថ្ងៃទី25 ដល់ថ្ងៃទី31 កក្កដា 2021) ចុងក្រោយនេះ ខ្ញុំមិនបានធ្វើការទេប៉ុន្តែខ្ញុំមានកន្លែងការងាររបស់ខ្ញុំ

① មាន ⟶ សូមប្តូរទៅលេខ 30

② មិនមាន ⟶ សូមប្តូរទៅលេខ 36

## ការចូលធ្វើការងារ

**30** ក្នុងរយៈពេលមួយសប្តាហ៍(ថ្ងៃទី25 ដល់ថ្ងៃទី31 កក្កដា 2021) ចុងក្រោយនេះ តើអ្វីជាការងារចំបងរបស់អ្នក?

| | | |
|---|---|---|
| 1) ឈ្មោះសហគ្រាស (កន្លែងការងារ) | | ឧទាហរណ៍) ភោជនីដ្ឋាន ○○ |
| 2) ឈ្មោះមុខងារ (តំណែង) | | ឧទាហរណ៍) អ្នកគិតលុយ |
| 3) កិច្ចការដែលខ្ញុំធ្វើ | | ឧទាហរណ៍) គិតលុយថ្លៃអាហារ ចេញវិក័យបត្រ |

※ ស្ថាប័នស្រាវជ្រាវជាអ្នកបំពេញ(តាមប្រភេទនៃការងារ) ☐

---

**31** នៅក្នុងក្រុមហ៊ុន(កន្លែងការងារ)នោះតើអ្នកបានធ្វើការជាក់ស្តែងប្រហែលជាប៉ុន្មានម៉ោង ក្នុងរយៈពេលមួយសប្តាហ៍(ថ្ងៃទី25 ដល់ថ្ងៃទី31 កក្កដា 2021) ចុងក្រោយនេះ

ម៉ោងដែលបានធ្វើការ : ☐☐☐☐ ម៉ោង

---

**32** តើកន្លែងការងារក្នុងលេខ **30** របស់អ្នកត្រូវនឹងចំណុចមួយណាខាងក្រោមនេះដែរ?

① កម្មករទូទៅ
② កម្មករបណ្តោះអាសន្ន
③ កម្មករធ្វើការគិតជាថ្ងៃ
④ អាជីវកម្មផ្ទាល់ខ្លួនដែលមានបុគ្គលិកផ្សេង
⑤ អាជីវកម្មផ្ទាល់ខ្លួនដែលគ្មានបុគ្គលិកផ្សេង
⑥ កន្លែងធ្វើការលក្ខណៈគ្រួសារដោយគ្មានប្រាក់កម្រៃដោយជួយពីសមាជិកនៅក្នុងគ្រួសារ

① កម្មករទូទៅ : គឺជាពលករដែលចុះកុងត្រាការងារលើសពីមួយឆ្នាំ ហើយចូលធ្វើការទៅតាមនីតិវិធីនៃការជ្រើសរើសបុគ្គលិកដែលបានកំណត់ ហើយជាអ្នកដែលទទួលនូវការអនុវត្តតាមគោលការណ៍គ្រប់គ្រងបុគ្គលិកក្រុមហ៊ុន និងទទួលប្រាក់បំណាច់ឆ្នាំ ឬប្រាក់រង្វាន់លើកទឹកចិត្តជាដើម។
② កម្មករបណ្តោះអាសន្ន : កម្មករដែលមានកិច្ចសន្យាការងារលើសពីមួយខែហើយតិចជាងមួយឆ្នាំ
③ កម្មករធ្វើការគិតជាថ្ងៃ : កម្មករដែលមានកិច្ចសន្យាការងារក្រោមមួយខែ
④ អាជីវកម្មផ្ទាល់ខ្លួនដែលមានបុគ្គលិកផ្សេង : អ្នកដែលមានបុគ្គលិកធ្វើការជាប្រចាំចាប់ពីមួយនាក់ឡើងទៅ
⑤ អាជីវកម្មផ្ទាល់ខ្លួនដែលគ្មានបុគ្គលិកផ្សេង : អ្នកធ្វើការខ្លួនឯងមិនប្រើបុគ្គលិកប្រចាំឬអ្នកធ្វើការជាមួយនឹងសមាជិកគ្រួសារដែលមិនទទួលប្រាក់កម្រៃ
⑥ កន្លែងធ្វើការលក្ខណៈគ្រួសារដោយគ្មានប្រាក់កម្រៃដោ : អ្នកដែលធ្វើការលើសពី 18 ម៉ោងក្នុងមួយសប្តាហ៍ក្នុងក្រុមហ៊ុនដែលមិនទទួលប្រាក់កម្រៃដោយសារជាសាច់ញាតិឬជាសមាជិករបស់ម្ចាស់អាជីវកម្ម

---

**33** តើអ្នកស្វែងរកកន្លែងការងារដូចនៅក្នុងលេខ **30** បានយ៉ាងដូចម្តេច?

① ទទួលការណែនាំពីគ្រួសារឬសាច់ញាតិ
② ទទួលការណែនាំពីគ្រួសារឬសាច់ញាតិរបស់ប្តីឬប្រពន្ធ
③ ទទួលការណែនាំពីមិត្តភ័ក្តិជនជាតិខ្មែរឬអ្នកស្គាល់គ្នា
④ ទទួលការណែនាំពីភ័ក្រ្តឬអ្នកជិតខាងជនជាតិកូរ៉េ
⑤ ទទួលការណែនាំពីស្ថាប័នសាធារណៈដូចជាមជ្ឈមណ្ឌលការងារជាដើម
⑥ ទទួលការណែនាំពីស្ថាប័នសាធារណៈដូចជាមជ្ឈមណ្ឌលការងារជាដើម
⑦ តាមរយៈបណ្តាញផ្សព្វផ្សាយ(សារពត៌មាន ឬ ទស្សនាវត្តី) ឬខិតប័ណ្ណ
⑧ អាជីវកម្មផ្ទាល់ខ្លួន
⑨ ផ្សេងៗ(                                        )

**34** កំឡុងពេលអ្នកធ្វើការនៅ**កន្លែងការងារលេខ** **30** តើអ្វីទៅជាផលវិបាកខ្លាំងបំផុតរបស់អ្នក? សូមជ្រើសរើសចំលើយ 1។

① ពិបាកក្នុងការសន្ទនាជាភាសាកូរ៉េ
② ជាការងារពិបាក និងគ្រោះថ្នាក់
③ ម៉ោងធ្វើការងារយូរខ្លាំងណាស់
④ ទទួលបានប្រាក់តិច
⑤ មានបញ្ហាជាមួយថ្នាក់លើឬមិត្តរួមការងារ
⑥ មានការរើសអើងជនបរទេស
⑦ ពិបាកក្នុងការចិញ្ចឹមកូន
⑧ ពិបាកក្នុងការធ្វើការងារជាមួយនឹងកិច្ចការនៅផ្ទះ
⑨ ផ្សេងៗ(                    )
⓪ មិនមានការលំបាកទេ

---

**35** **ក្នុងរយៈពេល 3ខែកន្លងមកនេះ(ថ្ងៃទី1 ឧសភា. ~ ថ្ងៃទី 31 កក្កដា 20201) តើប្រាក់កម្រៃ ឬប្រាក់ឈ្នួលជាមធ្យមប្រចាំខែ(មុនពេលបង់ពន្ធ)**ដែលអ្នកទទួលបាននៅ**កន្លែងការងារដូចក្នុងលេខ** **30** មានចំនួនប៉ុន្មាន?

① ក្រោម 50ម៉ឺនវ៉ុន
② ពី50 ~ 100ម៉ឺនវ៉ុន
③ ពី100 ~ 150ម៉ឺនវ៉ុន
④ ពី150 ~ 200ម៉ឺនវ៉ុន
⑤ ពី200 ~ 250ម៉ឺនវ៉ុន
⑥ ពី250 ~ 300ម៉ឺនវ៉ុន
⑦ ពី300 ~ 350ម៉ឺនវ៉ុន
⑧ ពី350 ~ 400ម៉ឺនវ៉ុន
⑨ ពី400 ~ 450ម៉ឺនវ៉ុន
⑩ ពី450 ~ 500ម៉ឺនវ៉ុន
⑪ លើសពី 500ម៉ឺនវ៉ុន
⓪ មិនបានទទួលប្រាក់កម្រៃ ឬ ប្រាក់ឈ្នួលទេ

▶▶ ក្រោយពេលឆ្លើយរួច សូមប្តូរទៅលេខ **39**

## សកម្មភាពស្វែងរកការងារ

**36** **ក្នុងរយៈពេល 4 សប្តាហ៍(ថ្ងៃទី4 ដល់ 31 កក្កដា 2021)ចុងក្រោយនេះ តើអ្នកធ្លាប់បានស្វែងរកការងារ**ដែរទេ?

① ធ្លាប់បានស្វែងរក
② មិនបានស្វែងរកទេ ⟶ សូមប្តូរទៅលេខ **39**

---

**37** ប្រសិនបើអ្នកមាន**ការងារថ្មីនៅក្នុងកំឡុងពេលសប្តាហ៍មុន(ថ្ងៃទី25 ដល់ 31 កក្កដា 2021)តើអ្នកអាចចាប់ផ្តើមធ្វើការងារ**បានដែរឬទេ?

① ចាប់ផ្តើមបាន
② ចាប់ផ្តើមអត់បានទេ

---

**38** **តើអ្នកមានផលវិបាកក្នុងការស្វែងរកកន្លែងការងារ**ក្នុងប្រទេសកូរ៉េដែរទេប្រសិនបើមានសូមជ្រើសរើសយកចម្លើយ**ទាំងអស់**ដែលត្រូវនឹងអ្នក?

① ដោយសារមិនសូវចេះនិយាយភាសាកូរ៉េ
② ដោយសារត្រូវមើលថៃកូននិងគ្រួសារ
③ ដោយសារគ្មានការងារដែលមានលក្ខខណ្ឌប្រាក់ឈ្នួលដែលចង់បានឬលក្ខខណ្ឌការងារត្រូវនឹងខ្ញុំ
④ ដោយសារគ្មានកន្លែងការងារនៅក្បែរផ្ទះខ្ញុំ
⑤ ដោយសារកម្រិតវប្បធម៌និងបទពិសោធន៍ការងារដែលខ្ញុំមាននៅប្រទេសរបស់ខ្ញុំគេមិនទទួលស្គាល់
⑥ ដោយសារខ្វះបទពិសោធន៍ការងារនៅក្នុងប្រទេសកូរ៉េ
⑦ ដោយសារខ្វះព័ត៌មានពាក់ព័ន្ធនឹងកន្លែងការងារ និងមិនស្គាល់ពីរបៀបចូលធ្វើការ
⑧ ដោយសារការរើសអើងជនបរទេស
⑨ ដោយសារមានការបដិសេធពីគ្រួសារ
⑩ ផ្សេងៗ(                    )
⓪ មិនមានផលលំបាកទេ

**39** តើអ្នកធ្លាប់មានបទពិសោធន៍នៃ**ប្រែប្រួលការងារ**ដូចខាងក្រោមដោយសារ**ការរីករាលដាលនៃកូវីដ19** ដែរទេ? ប្រសិនបើមានសូមជ្រើសរើសយក**ទាំងអស់**?
※ ប៉ុន្តែក្នុងករណីជ្រើសរើសយកលេខសូន្យ⓪ នោះមិនអាចឆ្លើយជាពហុចម្លើយបានឡើយ(អាចឆ្លើយបានតែមួយប៉ុណ្ណោះ

① ការបណ្ដេញចេញ
② ក្បៀយធន់
③ សម្រាកការងារ · ព្យួរការងារ
④ មិនមាន(ក្នុងករណីដែលមានដូចក្នុង①~③, មិនមានការផ្លាស់ប្ដូរ, មិនធ្លាប់មានបទពិសោធន៍ចូលធ្វើការទេ)

## V ករណីទូទៅផ្សេងៗ

### ការប្រើប្រាស់ភាសា

**40** ខាងក្រោមនេះគឺជាសំណួរអំពីការប្រើប្រាស់ភាសានៅក្នុងផ្ទះ។ សូមគូសសញ្ញា ✓ នៅកន្លែងដែលត្រូវនឹងអ្នកតាមសំណួរនីមួយៗ។
※ សូមឆ្លើយតបដោយផ្អែកលើគ្រួសារដែលរស់នៅជាមួយអ្នក។

| ខ្លឹមសារ | អញ្ចឹងខ្លាំង | ភាគច្រើនអញ្ចឹង | ធម្មតា | មិនសូវអញ្ចឹងទេ | មិនអញ្ចឹងសោះ | មិនមានចម្លើយ |
|---|---|---|---|---|---|---|
| 1) គ្រួសាររបស់ខ្ញុំលើកទឹកចិត្តឲ្យខ្ញុំប្រើប្រាស់ភាសារបស់ខ្ញុំ | ① | ② | ③ | ④ | ⑤ | ⓪ (រស់នៅម្នាក់ឯង/មិនរស់នៅជាមួយគ្រួសារ) |
| 2) គ្រួសាររបស់ខ្ញុំលើកទឹកចិត្តឲ្យកូនប្រើប្រាស់ភាសារបស់ខ្ញុំ | ① | ② | ③ | ④ | ⑤ | ⓪ (រស់នៅម្នាក់ឯង/មិនរស់នៅជាមួយគ្រួសារ) |
| 3) បើអាចបានខ្ញុំនិយាយភាសាខ្មែរជាមួយកូនរបស់ខ្ញុំ | ① | ② | ③ | ④ | ⑤ | ⓪ (រស់នៅម្នាក់ឯង/មិនរស់នៅជាមួយគ្រួសារ) |

### ការស្គាល់អំពីតួនាទីរបស់កូនប្រុសស្រី

**41** តើអ្នកគិតយ៉ាងដូចម្ដេចចំពោះខ្លឹមសារខាងក្រោម? សូមគូសសញ្ញា ✓ នៅកន្លែងដែលត្រូវនឹងអ្នកតាមសំណួរនីមួយៗ។

| ខ្លឹមសារ | អញ្ចឹងខ្លាំង | ភាគច្រើនអញ្ចឹង | ធម្មតា | មិនសូវអញ្ចឹងទេ |
|---|---|---|---|---|
| 1) ជីវភាពគ្រួសាររបស់ខ្ញុំភាគច្រើនគឺបុរសជាអ្នកទទួលខុសត្រូវ | ① | ② | ③ | ④ |
| 2) ការឯករាជ្យផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីមានសារៈសំខាន់ណាស់ | ① | ② | ③ | ④ |
| 3) ស្ត្រីត្រូវតែដាក់អាទិភាពទៅលើការមើលថែកូនតូចរបស់ខ្លួនជាជាងការធ្វើការងារនៅក្រុមហ៊ុន | ① | ② | ③ | ④ |
| 4) បុរសត្រូវតែអាចមើលកូនដោយមិនចាំបាច់មានជំនួយពីអ្នកដទៃ | ① | ② | ③ | ④ |

☞ សូមឆ្លើយប្រសិនបើអ្នកមិនទាន់មានសញ្ជាតិកូរ៉េ. បើមានសញ្ជាតិកូរ៉េ សូមប្តូរទៅលេខ 44

## សិទ្ធិរស់នៅ និង ការចូលសញ្ជាតិ

**42** តើប្រភេទនៃសិទ្ធិរស់នៅបច្ចុប្បន្នរបស់អ្នកគឺជាអ្វី?

① អចិន្ត្រៃយ៍(F-5)
② ស្ត្រីរៀបការ(F-6), ប្តីឬប្រពន្ធរបស់ជនជាតិកូរ៉េ(F-2-1)
③ ស្នាក់នៅ(F-2, លើកលែង F-2-1)
④ រស់នៅតាមរយៈការមកលេង(F-1)
⑤ ជនជាតិកូរ៉េនៅបរទេស(F-4)
⑥ អ្នកធ្វើការងារជំនាញ(ពីE-1 ដល់E-7)
⑦ ទស្សនកិច្ចការងារ(H-2)
⑧ ផ្សេងៗ

→ **42-1** តើនៅពេលខាងមុខអ្នកមានគម្រោងចង់ទទួលសិទ្ធិអចិន្ត្រៃយ៍នៅក្នុងប្រទេសកូរ៉េដែលទេ

① ខ្ញុំនឹងយកសិទ្ធិរស់នៅអចិន្ត្រៃយ៍
② ខ្ញុំមិនមានគម្រោងទទួលសិទ្ធិរស់នៅអចិន្ត្រៃយ៍ទេ
③ ខ្ញុំមិនដឹងទេ

**43** តើអ្នកមានគម្រោងក្នុងការដូរយកសញ្ជាតិកូរ៉េដែរទេ?

① នឹងទទួលយកសញ្ជាតិកូរ៉េ ② ខ្ញុំអត់មានគម្រោងយកសញ្ជាតិកូរ៉េទេ ③ ខ្ញុំមិនដឹងទេ

## ស្ថានភាពសុខភាព និង តម្រូវការសេវាកម្មសុខភាព

**44** តើស្ថានភាពទូទៅនៃសុខភាពរបស់អ្នកយ៉ាងម៉េចដែរ

① ល្អណាស ② ល្អ ③ ធម្មតា ④ មិនសូវល្អ ⑤ មិនល្អទេ

**45** ក្នុងរយៈពេល1ឆ្នាំកន្លងមកនេះ(ថ្ងៃទី1 សីហា 2020 ~ ដល់ថ្ងៃទី31 កក្កដា 2021) តើអ្នកធ្លាប់មានអារម្មណ៍ថាកើតទុក្ខ ឬអស់សង្ឃឹម ដែលស្ទើរតែជីវិតរស់នៅប្រចាំថ្ងៃលំបាកខ្លាំងមែនទែនលើសពី 2សប្តាហ៍ទេ?

① មិនធ្លាប់បែបហ្នឹងទេ ② មានអារម្មណ៍ម្តងម្កាល ③ មានអារម្មណ៍ញឹកញាប់ ④ មាអារម្មណ៍ញឹកញាប់ណាស់

**46** ក្នុងរយៈពេល1ឆ្នាំកន្លងមកនេះ(ថ្ងៃទី1 សីហា 2020 ~ ដល់ថ្ងៃទី31 កក្កដា 2021) តើអ្នកធ្លាប់មានបទពិសោធន៍ដែលអ្នកឈឺ ហើយចង់ទៅមន្ទីរពេទ្យតែទៅមិនបានដែរឬទេ?

① ធ្លាប់ → **46-1** បើកធ្លាប់មានតើអ្វីទៅជាមូលហេតុធំបំផុតដែលអ្នកមិនអាចទៅមន្ទីរពេទ្យបាន? សូមជ្រើសរើសចម្លើយមួយ។

① ដោយសារមិនចេះនិយាយភាសាកូរ៉េ
② ដោយសារមិនមានមន្ទីរពេទ្យនៅក្បែរ
③ ដោយសារបន្ទុកនៃថ្លៃព្យាបាល
④ ដោយសារមិនដឹងថាត្រូវទៅមន្ទីរពេទ្យមួយណា
⑤ ដោយសារនីតិវិធីប្រើប្រាស់មានភាពស្មុគស្មាញ
⑥ ដោយសារការងារនៅក្រុមហ៊ុនរវល់
⑦ ដោយសារត្រូវមើលកូននិងធ្វើកិច្ចការផ្ទះ
⑧ ផ្សេងៗ( )

② មិនធ្លាប់ទេ

## កម្រិតនៃការពេញចិត្តជីវិតរស់នៅប្រចាំថ្ងៃ

**47** នៅពេលដែលអ្នកពិចារណាលើជីវិតរស់នៅរបស់អ្នកតើអ្នកពេញចិត្តនឹងជីវិតនាពេលបច្ចុប្បន្ននេះប៉ុណ្ណា?

① ពេញចិត្តខ្លាំង ② ពេញចិត្តតិចតួច ③ ធម្មតា ④ មិនសូវពេញចិត្តទេ ⑤ មិនពេញចិត្តសោះ

## ឋានៈនៅក្នុងសង្គម

**48** នៅពេលអ្នកសម្លឹងមើលផ្នែកជាច្រើន(ប្រាក់ចំណូល ទ្រព្យសម្បត្តិ កម្រិតវប្បធម៌ និងការងារ) តើអ្នកគិតថាគ្រួសាររបស់អ្នកស្ថិតនៅក្នុងឋានៈមួយណានៅក្នុងសង្គម?

1 លើ — ① លើ ② ក្រោម
2 កណ្ដាល — ① លើ ② ក្រោម
3 ក្រោម — ① លើ ② ក្រោម

## ការត្រៀម និង ភាពភ័យខ្លាចដោយសារវ័យចាស់ជរា

**49** តើអ្នកកំពុងត្រៀមសម្រាប់វ័យចាស់ជរារបស់អ្នកដែរឬទេ? បើអ្នកកំពុងត្រៀមសូមសរសេរនូវអ្វីដែលជាគោលចំបង និង ចំណុចបន្ថែម ក្នុងចំណោមការត្រៀមនោះ។

※ ប្រាក់ជំនួយជាតិ(ការធានាជីវិតរស់នៅមូលដ្ឋាន ជាដើម) មិនមែនជាវិធីដែលសាមីខ្លួនត្រៀមសម្រាប់វ័យចាស់ជរាទេ ដូច្នេះហើយ ទើបមិនមានបូកបញ្ចូលនៅក្នុងការត្រៀមសម្រាប់វ័យចាស់ជរាឡើយ។

① កំពុង(បាន)ត្រៀម ② មិនទាន់បានត្រៀមទេ

គោលចំបង (ទី1) [ ] ណុចបន្ថែម (ទី2) [ ]

1. ប្រាក់សោធនជាតិ
2. ប្រាក់សោធនសាធារណៈផ្សេងៗទៀត (មន្ត្រី ទាហាន គ្រូបង្រៀន)
3. ប្រាក់សោធននិវត្តន៍ឯកជន (ប្រាក់សោធនផ្ទាល់ខ្លួនតាមរយៈធនាគារក្រុមហ៊ុនធានារ៉ាប់រង។ ល។)
4. ប្រាក់ចូលនិវត្តន៍ (ប្រាក់បំណាច់ឆ្នាំ ប្រាក់សោធនចូលនិវត្តន៍)
5. ការសន្សំប្រាក់ ការធានារ៉ាប់រងការសន្សំ
6. ការគ្រប់គ្រងអចលនទ្រព្យ
7. ភាគហ៊ុនភាគហ៊ុន ជាដើម
8. ផ្សេងទៀត (                    )

**50** តើអ្នកមានអារម្មណ៍ថាខ្វល់ខ្វាយ ឬ ភ័យខ្លាចពាក់ព័ន្ធនឹងចំណុចខាងក្រោមអំពីវ័យចាស់ជរាប៉ុណ្ណា?

| ខ្លឹមសារ | អញ្ជឹងខ្លាំង | ភាគច្រើនអញ្ជឹង | ធម្មតា | មិនសូវអញ្ជឹងទេ | មិនអញ្ជឹងសោះ |
|---|---|---|---|---|---|
| 1) ផលវិបាកផ្នែកសេដ្ឋកិច្ច | ① | ② | ③ | ④ | ⑤ |
| 2) គ្មានការងារធ្វើ ឬ ភាពភ័យខ្លាចដោយសារការងារ | ① | ② | ③ | ④ | ⑤ |
| 3) បញ្ហាសុខភាព | ① | ② | ③ | ④ | ⑤ |
| 4) ភាពឯកោ និង ភាពដាច់ដោយឡែក | ① | ② | ③ | ④ | ⑤ |

## សូមអរគុណដែលលោកអ្នកបានចំណាយពេលវេលាដ៏មានតំលៃឆ្លើយនឹងសំនួរទាំងនេះ។

※ សូមសរសេរឈ្មោះ និង លេខទូរស័ព្ទរបស់បុគ្គលដែលឆ្លើយសំនួរ

(លេខទូរស័ព្ទគឺប្រើសំរាប់តែការសួរបន្ថែមពាក់ព័ន្ធនឹងខ្លឹមសារក្នុងកម្រងសំនួរនេះប៉ុណ្ណោះ)

| | |
|---|---|
| ឈ្មោះ | |
| លេខទូរស័ព្ទ | (          ) – (          ) – (          ) |
| ថ្ងៃឆ្លើយចំលើយ | 2021ឆ្នាំ (          )ខែ (          )ថ្ងៃ |